**THE STATE EDUCATION DEPARTMENT** / THE UNIVERSITY OF THE STATE OF NEW YORK / ALBANY, NY 12234

Jhone M. Ebert, Senior Deputy Commissioner for Education Policy
Education Building, Room 2M EB (518) 474-3862
89 Washington Avenue
Albany, NY 12234
jhone.ebert@nysed.gov

ថ្ងៃទី 27 ខែកុម្ភៈ ឆ្នាំ 2017

ជូនចំពោះ ៖ ស្នងការមណ្ឌលសិក្សាស្រុក
ស្នងការសាលារៀនសាធារណៈ
នាយកសាលាសាធារណៈ
រដ្ឋបាលរបស់សាលាឯកជន និងសាលារៀនឯករាជ្យទទួលមូលនិធិរដ្ឋ

ពី ៖ Jhone M. Ebert, ស្នងការរងជាន់ខ្ពស់

កម្មវត្ថុ ៖ គោលការណ៍ណែនាំ និងធនធានសម្រាប់ប្រយុទ្ធប្រឆាំងការបង្កការរំខាន ការសម្លុតគម្រាម និងការរើសអើងនៅក្នុងសាលាពាក់ព័ន្ធនឹងសកម្មភាពថ្មីៗពាក់ព័ន្ធនឹងអន្តោប្រវេសន៍

ក្នុងសប្តាហ៍ថ្មីៗកន្លងទៅនេះ មានសេចក្តីរាយការណ៍ជាច្រើនស្តីអំពីហេតុការណ៍សម្លុតគម្រាម ការរើសអើង និងការរំខាននៅតាមសាលាទូទាំងប្រទេស បានលេចឡើងនៅតាមទំព័រសារព័ត៌មាននានា ។ លើសពីនេះ គឺមានសកម្មភាពថ្មីៗពាក់ព័ន្ធនឹងអន្តោប្រវេសន៍ ដែលបានអនុវត្តន៍ឡើងដោយមន្ត្រីសហព័ន្ធ ដែលបានបង្កឲ្យមានភាពភ័យខ្លាច និងការភាន់ភាំងទូទាំងប្រទេស ។ ក្រសួងអប់រំរដ្ឋញូយ៉ក (New York State Education Department (“NYSED” ឬហៅថា “ក្រសួង - Department”)) ចាត់សកម្មភាពយ៉ាងម៉ឺងម៉ាត់ដើម្បីសម្របសម្រួលបរិយាកាសសាលា ដែលសិស្សត្រូវមករៀនជារៀងរាល់ថ្ងៃ ។ នៅរដ្ឋញូយ៉ក អ្នកតស៊ូមតិ ឪពុកម្តាយសិស្ស និងបុគ្គលិកសាលា បានពឹងពាក់ឲ្យក្រសួងពង្រីក និងកសាងបន្តពីគោលការណ៍ណែនាំ និងធនធានដែលមានស្រាប់ ដើម្បីប្រយុទ្ធប្រឆាំងនឹងការបង្កការរំខាន ការសម្លុតគម្រាម និងការរើសអើង ក៏ដូចជាដើម្បីបង្កើនកិច្ចខិតខំប្រឹងប្រែងដើម្បីកសាង និងរក្សាឲ្យបាននូវបរិយាកាសវិជ្ជមានរបស់សាលា ដោយអនុលោមទៅតាមក្រមសេចក្តីថ្លៃថ្នូរបស់សិស្សទាំងអស់ ((Dignity for All Students Act (“DASA” ឬហៅថា “ក្រមសេចក្តីថ្លៃថ្នូ - Dignity Act”)) ។

ក្រមសេចក្តីថ្លៃថ្នូរបស់រដ្ឋញូយ៉ក (New York State’s Dignity Act) ត្រូវបានចុះហត្ថលេខា ឲ្យក្លាយជាច្បាប់ក្នុងឆ្នាំ 2012 ដើម្បីផ្តល់ឲ្យសិស្សនូវបរិយាកាសប្រកបដោយសុវត្ថិភាព និងការគាំពារ ដែលរួចផុតពីការរើសអើង ការបង្កការរំខាន និងការសម្លុតគម្រាម នៅក្នុងបរិវេណសាលារៀន រថយន្តសាលារៀន និង/ឬនៅតាមទីកន្លែងប្រារព្ធកម្មវិធីរបស់សាលា ហើយច្បាប់នេះត្រូវបានធ្វើវិសោធនកម្មក្នុងឆ្នាំ 2013 ដើម្បីបញ្ចូលការសម្លុតគម្រាមតាមអ៊ិនធឺណិតផងដែរ[1] ។ ច្បាប់នេះ តម្រូវឲ្យសាលារៀនទាំងអស់ត្រូវផ្តល់ឲ្យសិស្ស បុគ្គលដែលស្ថិតក្នុងតួនាទីជាឪពុកម្តាយសិស្ស និងបុគ្គលិកសាលា នូវព័ត៌មាន ស្តីអំពី DASA និងបង្កើតគោលនយោបាយ ព្រមទាំងទម្រង់ការ ដែលធានាឲ្យមានបរិយាកាសសាលាប្រកបដោយសុវត្ថិភាព ។ ជាពិសេស DASA តម្រូវឲ្យមណ្ឌលសិក្សាស្រុក (school districts) បង្កើតក្រមសីលធម៌ (Codes of Conduct) ដែលហាមឃាត់មិនឲ្យមានការបង្កការរំខាន ការសម្លុតគម្រាម (រួមទាំងការសម្លុតគម្រាមតាមអ៊ិនធឺណិត)

---

[1] សម្រាប់គោលការណ៍ណែនាំ និងធនធានបន្ថែម ពាក់ព័ន្ធនឹងក្រមសេចក្តីថ្លៃថ្នូ (Dignity Act) សូមចូលទស្សនាអាសយដ្ឋាន http://www.p12.nysed.gov/dignityact/ ។

ព្រមទាំងការរើសអើងចំពោះសិស្ស ដោយសិស្សផ្សេងទៀត ឬដោយបុគ្គលិកសាលា ក៏ដូចជាគោលការណ៍ដើម្បីឆ្លើយតបចំពោះហេតុការណ៍ការរើសអើង និងការបង្កការរំខាន ហើយត្រូវរាយការណ៍ហេតុការណ៍បែបនេះទៅកាន់ NYSED ។

ដូចអ្វីដែលបានរៀបរាប់ខាងក្រោម NYSED ជាមួយនឹងការិយាល័យអគ្គមេធាវីប្រចាំរដ្ឋញូយ៉ក (New York State Office of the Attorney General (“OAG”)) បានចេញគោលការណ៍ណែនាំ និងធនធាន ដើម្បីជាស្មារតីជំនួយដល់បុគ្គលិកសាលា សិស្ស និងឪពុកម្តាយសិស្ស ធ្វើការរាយការណ៍ និងដោះស្រាយហេតុការណ៍ការបង្កការរំខាន ការសម្លុតគម្រាម និងការរើសអើង ។ ឯកសារជាគោលការណ៍ណែនាំដែលបានបង្កើតឡើងរួមគ្នាដោយ NYSED និង OAG នាខែសីហា ឆ្នាំ 2016 គឺ មានរួមបញ្ចូលនូវសំណុំបែបបទគំរូសម្រាប់រាយការណ៍ និងស៊ើបអង្កេតហេតុការណ៍ DASA[2] ដែលបានកើតឡើង ។ ក្រសួង មានបំណងបង្កើនកិច្ចការដ៏សំខាន់មួយនេះ ដោយការក្រើនរំឭកសាលា និងគ្រួសារសិស្សឲ្យបានជ្រាបថា គោលការណ៍ណែនាំ និងជំនួយបច្ចេកទេសស្តីអំពី DASA ព្រមទាំងសាលាមានសុវត្ថិភាព និងការគាំពារ គឺមានផ្តល់ជូនពីក្រសួង ។

NYSED សូមលើកទឹកចិត្តឲ្យមណ្ឌលសិក្សាស្រុក ឪពុកម្តាយ និងអាណាព្យាបាលសិស្ស ដែលមានសំណួរស្តីអំពី DASA ឲ្យទំនាក់ទំនងជាមួយនឹង NYSED ដើម្បីសុំគោលការណ៍ណែនាំ និងជំនួយបច្ចេកទេស ស្តីអំពីប្រូតូកូល និងនីតិវិធីនៃការស៊ើបអង្កេតសមរម្យ ព្រមទាំងភាពជោគជ័យនានា ក្នុងការបង្កើត និងការរក្សាបាននូវបរិយាកាសសាលាប្រកបដោយសុវត្ថិភាព និងមានការគាំពារ ។ អ្នកអាចទាក់ទងជាមួយនឹងក្រសួងតាម ៖

- ការិយាល័យអប់រំពីរភាសា និងភាសាពិភពលោក (Office of Bilingual Education and World Languages (OBEWL)) តាមទូរស័ព្ទ (718) 722-2445 ឬអ៊ីម៉េល obewl@nysed.gov *ឬ*
- ការិយាល័យសេវាកម្មគាំពារសិស្ស (Office of Student Support Services (SSS)) តាមលេខ (518) 486-6090 ឬអ៊ីម៉េល studentsupportservices@nysed.gov ។

ជាបន្ថែម ចំពោះអ្នកដែលមានសំណួរស្តីអំពី DASA ដែលត្រូវការជំនួយផ្នែកភាសា អាចទាក់ទងទូរស័ព្ទទាន់ហេតុការណ៍មកកាន់បណ្តាញធនធានការអប់រំពីរភាសាប្រចាំតំបន់ (Language Regional Bilingual Education Resource Network (RBERN)) ដែលមានការិយាល័យនៅក្នុងទីតាំងសកលវិទ្យាល័យរដ្ឋញូយ៉ក (New York University (“NYU”)) ដោយ ៖

- បំពេញសំណុំបែបបទការសាកសួរនៅទីនេះ
- ទូរស័ព្ទ ៖ (800) 469-8224
- ទូរសារ ៖ (212) 995-4199
- អ៊ីម៉េល ៖ nysparenthotline@nyu.edu
- សំបុត្រ ៖ NYS ELL Parent Hotline Team<br>c/o NYS Statewide Language RBERN at NYU MetroCenter<br>726 Broadway – 5th Floor<br>New York, NY 10003

[2] គោលការណ៍ណែនាំនេះ អាចរកបាននៅឯ http://www.p12.nysed.gov/dignityact/documents/SED-AGLttrandGuidance8-31-16.pdf ។

បុគ្គលគ្រប់គ្នាក៏អាចប្តឹងឧទ្ធរណ៍ចំពោះសកម្មភាពរបស់មណ្ឌលសិក្សាស្រុកផងដែរ ដោយអនុលោមទៅតាមច្បាប់អប់រំ (Education Law) វគ្គទី 310 ។ ច្បាប់អប់រំវគ្គទី 310 បានបញ្ជាក់ថា ភាគីណាដែលគិតថាខ្លួនឯងទទួលរងគ្រោះដោយសារសកម្មភាពដែលបានធ្វើឡើងក្នុងពេលប្រជុំរបស់មណ្ឌលសិក្សាស្រុក ឬសកម្មភាពដែលបានប្រព្រឹត្តិឡើងដោយអាជ្ញាធរសាលា អាចប្តឹងឧទ្ធរណ៍ទៅកាន់ស្នងការផ្នែកអប់រំ (Commissioner of Education) ដើម្បីពិនិត្យឡើងវិញនូវសកម្មភាពបែបនេះ ។ ព័ត៌មានអំពីការប្តឹងឧទ្ធរណ៍ មានផ្តល់ជូនជាភាសាអង់គ្លេស អេស្ប៉ាញ អារ៉ាប់ ចិន (បែបសម័យ) បេងកាលី និងក្រេអូលហៃទី តាមអាសយដ្ឋាន ៖ www.counsel.nysed.gov ។

សូមមេត្តាចំណាំទុកថា ក្រសួងយើងខ្ញុំប្តេជ្ញាចិត្តការពារឲ្យបាននូវឯកជនភាពចំពោះព័ត៌មានកម្រិតអត្តសញ្ញាណសិស្ស ហើយចាត់ចែងព័ត៌មានបែបនេះដោយអនុលោមទៅតាមច្បាប់ និងបទបញ្ញត្តិឯកជនភាពទាំងអស់ដែលអាចអនុវត្តបាន បូករួមទាំងក្រមសិទ្ធិការអប់រំក្រុមគ្រួសារ និងក្រមឯកជនភាព (Family Educational Rights and Privacy Act (“FERPA”)) របស់សហព័ន្ធ ។

ក្រសួង នឹងបញ្ចេញធនធានសម្រាប់ឪពុកម្តាយ អាណាព្យាលសិស្ស និងបុគ្គផ្សេងៗទៀតដែលចាប់អារម្មណ៍ចំពោះ DASA ដោយបកប្រែជាភាសាសំខាន់ៗចំនួនដប់ដែលប្រើទូទាំងរដ្ឋញូយ៉ក ។

លើសពីនេះ NYSED ក៏បានកំណត់ឃើញនូវធនធាន និងឧបករណ៍នានាដូចខាងក្រោម ដែលអាចជាជំនួយចំពោះបុគ្គលិកសាលា សិស្ស ឪពុកម្តាយសិស្ស និងសហគមន៍ផងដែរ ។ សូមមេត្តាប្រើធនធានទាំងអស់នេះទៅតាមសភាពការណ៍ដែលអាចប្រើបាន ហើយសូមចូលរួមជាមួយយើងខ្ញុំដើម្បីធានាឲ្យបាននូវសុវត្ថិភាព និងសុខភាពរបស់សិស្សទាំងអស់ ដោយការយកឧបករណ៍ទាំងអស់នេះ ទៅប្រើឲ្យស្របជាមួយគោលបំណង និងតម្រូវការរបស់សហគមន៍សាលារបស់អ្នក ។

- លិខិតរបស់ NYSED និងអគ្គមេធាវីរដ្ឋញូយ៉ក ផ្ញើទៅកាន់ស្នងការមណ្ឌលសិក្សាស្រុក និងគោលការណ៍ណែនាំ ៖ http://www.p12.nysed.gov/dignityact/documents/SED-AGLttrandGuidance8-31-16.pdf
- ការដោះស្រាយចំពោះការសម្លុតគម្រាម ការបង្កការរំខាន ការបំភិតបំភ័យ និងការរើសអើងនៅក្នុងសាលារបស់យើង ៖ http://www.p12.nysed.gov/dignityact/documents/PreventBullyingInYourSchool_Nov2016.pdf
- ម៉ូដែលសម្ភារៈបណ្តុះបណ្តាល ដើម្បីជួយមណ្ឌលសិក្សាស្រុក ក្នុងការបណ្តុះបណ្តាលបុគ្គលិករបស់ខ្លួន ៖ https://ag.ny.gov/sites/default/files/dasa_training_materials_final_-_8.30.16.pdf
- ក្រមសេចក្តីថ្លៃថ្នូរបស់សិស្សទាំងអស់ បូករួមទាំង “ធនធាន និងសេចក្តីណែនាំចំពោះការអនុវត្តល្អសម្រាប់រដ្ឋបាល និងបុគ្គលិកសាលា” (Resource and Promising Practices Guide for School Administrators & Faculty) ដោយមានគោលការណ៍ណែនាំ និងឧបករណ៍បន្ថែម ចំពោះការបង្កើតសាលាដែលមានសុវត្ថិភាព និងមានការគាំពារ ៖ http://www.p12.nysed.gov/dignityact
- ការភ្ជាប់ធនធានបន្ទាន់ចំពោះមជ្ឈមណ្ឌលរដ្ឋញូយ៉ក សម្រាប់ការអត់ធ្មត់ចំពោះការបង្រៀន (New York State Center for School Safety Quick Link Resources for Teaching Tolerance) និងការរក្សាបាននូវបរិយាកាសសិក្សាប្រកបដោយសុវត្ថិភាព និងសុខភាព ៖ http://www.nyscfss.org/#!quick-links/c13iz

- ព័ត៌មាន NYSED ស្តីអំពីការធ្វើផែនការឆ្លើយតបជាមួយនឹងគ្រាអាសន្ននៅសាលា និងធនធានសុខភាពផ្លូវចិត្តសម្រាប់សាលា (School Emergency Response Planning and Mental Health Resources for Schools)៖ http://www.p12.nysed.gov/sss/ssae/schoolsafety/save/
- ទំព័រមជ្ឈមណ្ឌលរដ្ឋញូយ៉កដើម្បីសុខភាពសាលា ដែលធ្វើបច្ចុប្បន្នភាពសុខភាពផ្លូវចិត្ត និង ធនធានការប្រឹក្សាយោបល់ (New York State Center for School Health updated Mental Health and Counseling Resources Page)៖ https://www.schoolhealthny.com/site/default.aspx?PageType=3&ModuleInstanceID=190&ViewID=7b97f7ed-8e5e-4120-848f-a8b4987d588f&RenderLoc=0&FlexDataID=108&PageID=126

ជាថ្មីម្តងទៀត សូមថ្លែងអំណរគុណចំពោះកិច្ចខិតខំប្រឹងប្រែងប្រចាំថ្ងៃរបស់អ្នកដើម្បីគាំពារសិស្ស ក្រុមគ្រួសារ និងសហគមន៍របស់យើងនៅទូទាំងរដ្ឋញូយ៉ក ។ នៅពេលណាយើងរួបរួមគ្នា យើងអាចធានាបានថាសិស្ស និងសហគមន៍សាលារបស់យើង មានសុវត្ថិភាព ព្រមទាំងទទួលបានការគាំពារនៅក្នុងបរិស្ថានសាលារបស់ពួកគេ ។ ដូចសព្វមួយដង សូមមេត្តាកុំស្ទាក់ស្ទើរក្នុងការទាក់ទងមកកាន់យើងខ្ញុំ បើអ្នកចង់ពិភាក្សាអំពីប្រធានបទសំខាន់ៗទាំងអស់នេះ ឬចង់ចែករំលែកក្តីបារម្ភណាមួយ ដោយការទាក់ទងមកកាន់ការិយាល័យសេវាកម្មគាំពារសិស្ស (Office of Student Support Services) តាមលេខ 518-486-6090 ឬតាមអ៊ីម៉េល studentsupportservices@nysed.gov ឬទាក់ទងមកកាន់ការិយាល័យអប់រំពីរភាសា និងភាសាបរទេស តាមលេខ 718-722-2445 ឬអ៊ីម៉េល obewl@nysed.gov ។